ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១៧៤
ចុះថ្ងៃទី២៣-០២-២០១២
សាលដីកា
លេខ: ១២ "ក្រ ll សវ"
ចុះថ្ងៃទី២៤-០២-២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឲ្យប្រើតាមក្រិត្យលេខ០៦ ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាកាជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១៤ ដោយមានសមាសភាពដូចខាងក្រោម:

## សមាសភាពក្រុមប្រឹក្សា

-ឯកឧត្តម [redacted] ប្រធាន
-លោក [redacted] ចៅក្រមប្រឹក្សា
-លោក [redacted] ចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ១៧៤ ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១២ ដែលមាន:

-ជនជាប់ចោទឈ្មោះ [redacted] ថុង ភេទប្រុស អាយុ ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីនគរបាល ស្រុកកណ្តាលស្ទឹង ទីលំនៅបច្ចុប្បន្នភូមិ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ៤នាក់ ទោសពីមុនគ្មាន។

ជាប់ចោទពីបទៈ ធ្វើឲ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិឃ្លាំងសម្បត្តិ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីយោធា ទីលំនៅ បច្ចុប្បន្នភូមិ [redacted]។

ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:

កាលពីថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១០ វេលាម៉ោង ១១និង ៣០នាទី មានអំពើធ្វើឲ្យខូចខាតមួយកើតមានឡើងនៅភូមិឃ្លាំងសម្បត្តិ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ ដែលបង្កឡើងដោយឈ្មោះ [redacted] ថុង។



៤៤១

ក្នុងពេលកើតហេតុនោះឈ្មោះ [redacted] ថុង បានប្រើប្រាស់ឧបករណ៍ដូចជា ពូថៅ និងញញួរបានវាយបំផ្លាញ របងបង្គោលថ្មព័ទ្ធដោយខ្សែបន្លាលួសដែលឈ្មោះ [redacted] លីសុគន្ធ ដាំហ៊ុំព័ទ្ធលើដីកម្មសិទ្ធិរបស់ខ្លួន។ អំពើរបស់ឈ្មោះ [redacted] ថុង ខាងលើនេះ គឺធ្វើឲ្យ ខូចខាតដោយដួលរលំ និងបាក់បង្គោលថ្មរបងអស់ចំនួន ២០ ដើម។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣០ ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១ របស់សាលាដំបូង ខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ផ្ដន្ទាទោសលើឈ្មោះ [redacted] ថុងដាក់ពន្ធនាគារកំណត់០៨ខែ (ប្រាំបីខែ) តែទោសនេះត្រូវព្យួរជម្មតា និងពិន័យជាប្រាក់ ១.០០០.០០០រៀល (មួយលានរៀល) ពីបទ ធ្វើឲ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិឃ្លាំងសម្បត្តិ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១០ តាមបញ្ញត្តិមាត្រា ៤១០ និងមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

២-អោយឈ្មោះ [redacted] ថុង សងថ្លៃការខូចខាតជាប្រាក់ចំនួន ៤០០ដុល្លាអាមេរិកនិងជម្ងឺចិត្តជាប្រាក់ចំនួន ៤.០០០.០០០រៀល(បួនលានរៀល) ទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] បណ្ដឹងទាមទារលើសពីនេះលើកចោល។

៣-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១១ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ បើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ថុង ជាជនជាប់ចោទសុំប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣០ ក ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១១ របស់សាលាដំបូង ខេត្តតាកែវត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ២៧ ក្រ॥ សវ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅៈ

១-ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ថុង ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣០ ក ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១១ របស់សាលាដំបូង ខេត្តតាកែវ ទុកជាបានការ។

៣-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៣ កំបាំងមុខជនជាប់ចោទ ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី។

បើកសិទ្ធិប្ដឹងតវ៉ាក្នុងកំណត់ច្បាប់។

-បានឃើញ បណ្ដឹងទាស់ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] ថុង សុំទាស់និង សាលដីកាលេខ ២៧ ក្រ॥ សវ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

-បានឃើញ របាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ថុង ( វត្តមាន )

ជនជាប់ចោទឈ្មោះ [redacted] ថុង បានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ នៅថ្ងៃកើតហេតុខ្លួនបានដកបង្គោលរបងថ្ម អស់ពីរបីចោលប៉ុណ្ណោះពីព្រោះឈ្មោះ [redacted] លីសុគន្ធ បានដាំរំលោភចូលដីរបស់ខ្លួន។

សំណូមពរ សុំលុបសំណងចោលនិងសុំរួចផុតពីបទចោទ។

-តំណាងមហាអយ្យការបានធ្វើសន្និដ្ឋានថាៈមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ សុំក្រុមប្រឹក្សាសំរេចតាមច្បាប់។

## សភាព្រហ្មទណ្ឌ យល់ឃើញថាៈ

១-បណ្តឹងទាស់ចុះថ្ងៃទី១២ខែកក្កដាឆ្នាំ២០១៣របស់ឈ្មោះ [redacted] ថុង ប្តឹងទាស់នឹងសាលដីកាព្រហ្មទណ្ឌលេខ ២៧ ក្រ៕ សវ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច បានធ្វើឡើងត្រឹមត្រូវក្នុងកំណត់ច្បាប់ សភាព្រហ្មទណ្ឌទទួលជំនុំជម្រះបាន យោងតាមមាត្រា៤១២ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ។

២-តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោលឃើញថា ជនជាប់ចោទឈ្មោះ [redacted] ថុង បានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ នៅថ្ងៃកើតហេតុនោះ ខ្លួនបានដកបង្គោលថ្មព័ទ្ធដោយខ្សែលួស ពីបីចោល ប៉ុណ្ណោះ ពីព្រោះឈ្មោះ [redacted] លីសុគន្ធ បានដាំរំលោភចូលដីរបស់ខ្លួន។ តាមចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ព្រមទាំងវត្ថុតាងនានាឃើញថាកាលពីថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១០ ជនជាប់ចោទពិតជាបានធ្វើសកម្មភាពដក និងវាយបំផ្លាញបង្គោលរបងរបស់ជនរងគ្រោះពិតមែន ដែលចំណុចនេះបង្ហាញឲ្យឃើញនូវអំពើ មានពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទពីបទធ្វើឲ្យ ខូចខាតដោយចេតនា បំពានមាត្រា ៤១០ នៃក្រម ព្រហ្មទណ្ឌដែលគប្បីផ្តន្ទាទោសជននេះតាមច្បាប់។

៣-សាលដីកាព្រហ្មទណ្ឌលេខ ២៧ ក្រ៕ សវ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ដែលសម្រេចមកនេះមានលើកសំអាងហេតុសព្វគ្រប់ និងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយគួរសភាព្រហ្មទណ្ឌតម្កល់ទុកជាបានការដដែល។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងទាស់ ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] ថុង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់តែបដិសេធចោលដោយទាស់គតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៧ ក្រសវ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ទុកជាបានការ។

៣-សាលដីកានេះជំនុំជម្រះកាលពីថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១៤ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខជនជាប់ចោទ។

បើកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកាស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធ ជួយសហការណ៍អនុវត្តសាលដីកានេះអោយបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ,ថ្ងៃទី០៤ខែ១២ឆ្នាំ២០១៤
ក្រឡាបញ្ជី

[redacted]